**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

លេខ ០០៤ សព្រក

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែ ផល្គុន ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២២

## សេចក្ដីប្រកាសព័ត៌មាន

យោងតាមសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងទេសចរណ៍មានសេចក្ដីសោមនស្សរីករាយសូមជម្រាបជូនដល់ប្រតិបត្តិករទេសចរណ៍ ទេសចរជាតិ អន្តរជាតិ និងអ្នកដំណើរផ្សេងៗទៀត ពីក្រៅប្រទេសទាំងអស់មកកម្ពុជា ដែលបានទទួលការចាក់វ៉ាក់សាំងពេញលេញ និងដូសមូលដ្ឋានឱ្យជ្រាបថា៖ ចាប់ពីថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ នេះតទៅ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដូចខាងក្រោម៖

១. លុបចោលលក្ខខណ្ឌតម្រូវឱ្យបង្ហាញលទ្ធផល PCR តេស្ត អវិជ្ជមានរយៈពេល ៧២ ម៉ោងមុនពេលមកដល់

២. លុបចោលលក្ខខណ្ឌតម្រូវឱ្យធ្វើតេស្តរហ័សពេលមកដល់

៣. ដាក់ឱ្យដំណើរការឡើងវិញនូវការផ្ដល់ទិដ្ឋាការពេលមកដល់ (Visa on Arrival) នៅគ្រប់ច្រកទ្វារអន្តរជាតិ ទាំងអស់តាមផ្លូវគោក ផ្លូវអាកាស និងផ្លូវទឹក ដោយបំពេញលក្ខខណ្ឌនានាដូចធ្លាប់បានអនុវត្ត មុនពេលវិបត្តិកូវីដ-១៩

នៅពេលមកដល់ ទេសចរជាតិ អន្តរជាតិ និងអ្នកដំណើរផ្សេងៗទៀត ត្រូវបង្ហាញវិញ្ញាបនបត្រ ឬឯកសារច្បាស់លាស់ បញ្ជាក់ការចាក់វ៉ាក់សាំងដូសមូលដ្ឋានពេញលេញចេញដោយអាជ្ញាធរមានសមត្ថកិច្ច។ សម្រាប់អ្នកធ្វើដំណើរដែលពុំទាន់ចាក់វ៉ាក់សាំងដូសមូលដ្ឋានពេញលេញ អាចទទួលបានការលើកលែង និងការសម្រួលខាងលើផងដែរ តែតម្រូវឱ្យធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃ នៅទីតាំងដែលកំណត់ដោយក្រសួងសុខាភិបាល ឬអាជ្ញាធរមានសមត្ថកិច្ច។

ទេសចរជាតិ អន្តរជាតិ និងអ្នកដំណើរផ្សេងៗទាំងអស់ ត្រូវបានលើកទឹកចិត្តឱ្យធ្វើតេស្តរហ័ស ដោយខ្លួនឯង មុនពេល ឬពេលមកដល់ និងអំឡុងពេលនៃការស្នាក់នៅកម្ពុជា និងតម្រូវឱ្យអនុវត្តឱ្យបានម៉ឺងម៉ាត់នូវវិធានសុខាភិបាល ៣កុំ ៣ការពារ ក៏ដូចជានីតិវិធីប្រតិបត្តិស្តង់ដាអប្បបរមា (Standard of Operating Procedures - SOPs) ដែលបានដាក់ចេញ និងអនុវត្តដោយក្រសួងទេសចរណ៍ តាមគ្រប់ប្រភេទសេវាកម្មទេសចរណ៍ទាំងអស់។

ក្រសួងទេសចរណ៍ស្នើឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ចូលរួមអនុវត្ត និងផ្សព្វផ្សាយសេចក្ដីប្រកាសព័ត៌មាននេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃនេះតទៅ។

**ក្រសួងទេសចរណ៍**

អគារលេខ៣A ផ្លូវលេខ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: +៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: +៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org